# អំណាចទន់នៃពិធីបុណ្យចូលឆ្នាំចិន

## ១- សេចក្តីផ្តើម

ពិធីបុណ្យចូលឆ្នាំចិនជាពិធីបុណ្យនិទាឃរដូវ ឬបុណ្យនៃរដូវផ្ការីក «Spring Festival» ដែលមានប្រវត្តិសាស្ត្រជាង២,០០០ឆ្នាំ។ ពិធីបុណ្យនិទាឃរដូវជាថ្ងៃឈប់សម្រាកដ៏សំខាន់បំផុតមួយនៅលើប្រតិទិនចិន។ ពិធីបុណ្យនិទាឃរដូវ ឬគេហៅថា chun jie ត្រូវបានប្រារព្ធដោយមនុស្សរាប់ពាន់លាននាក់។[1] ពាក្យថា Chun Jie ត្រូវបានបកប្រែពីភាសាអង់គ្លេសថាបុណ្យនិទាឃរដូវ (ចូលឆ្នាំចិន ឬចូលឆ្នាំថ្មី)។[2] ពិធីបុណ្យនេះ នៅខ្មែរយើងប្រាកដជាឮពាក្យថា 新年快乐 Xīnnián kuàilè បកប្រែភាសាខ្មែរថា សួស្តីឆ្នាំថ្មី នឹងភ្ជាប់ជាមួយពាក្យជូនពរដូចជា 恭喜发财 Gōngxǐ fācái បកប្រែភាសាខ្មែរថា សូមឱ្យរកស៊ីមានបាន, 身体健康 Shēntǐ jiànkāng សូមឱ្យមានសុខភាពល្អ និង 万事如意 Wànshì rúyì សូមឱ្យបានសម្រេចដូចបំណងជាដើម។

ឫសគល់នៃពិធីបុណ្យ បើយោងទៅតាមរឿងព្រេងទេវកថា មានទេវសត្វមួយក្បាលឈ្មោះ Nian បានបំផ្លាញភូមិ និងស៊ីដំណាំ ស៊ីសត្វពាហនៈ និងមនុស្ស។ ក្រោយមកអ្នកភូមិយល់ឃើញថា សត្វ Nian ខ្លាចពណ៌ក្រហមនិងសំឡេងខ្លាំង ដូច្នេះដើម្បីបន្លាចសត្វ Nian មនុស្សក៏បន្លឺសំឡេងខ្លាំងៗ ដោយដុតផាវ។ ពួកគេស្លៀកសម្លៀកបំពាក់ពណ៌ក្រហម ហើយព្យួរគោមពណ៌ក្រហមនៅខាងក្រៅ។ ប្រហែលជាដោយសារតែហេតុនេះហើយទើបពណ៌ក្រហមបានក្លាយមកជានិមិត្តរូបនៃសំណាងរបស់ជនជាតិចិន។[3]

នៅសម័យទំនើប ប្រទេសចិនបានប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីប្រចាំឆ្នាំរបស់ខ្លួន ចាប់តាំងពីឆ្នាំ១៩៨៤។ រហូតមកដល់ពេលនេះ ពិធីបុណ្យចូលឆ្នាំថ្មី តាមច័ន្ទគតិបានក្លាយជាផ្នែកមួយនៃវប្បធម៌ចិន និងមានអត្ថន័យលើសពីនេះ។[4] គំរូនៃការអភិវឌ្ឍរបស់ប្រទេសចិនក៏ជាមាគ៌ាសម្រាប់ប្រទេសផ្សេងទៀត ក្នុងការស្វែងរកទំនើបកម្មកំណើនសេដ្ឋកិច្ច។[5]

អំណាចទន់របស់ចិន បានចាក់គ្រឹះកាន់តែរឹងមាំថែមទៀត នៅពេលដែលមានសកម្មភាពថ្នាក់ដឹកនាំចិននៅលើឆាកអន្តរជាតិ។ ជាក់ស្តែង នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ លោកប្រធានាធបតី ស៊ី ជីនពីង បានដាក់ចេញនូវ «គំនិតផ្តួចផ្តើមអរិយធម៌សកល» ដើម្បីដោះស្រាយបញ្ហារួមរបស់មនុស្សជាតិ និងលើកកម្ពស់សន្តិភាពពិភពលោកផ្អែកលើគោលការណ៍ស្នូលចំនួន៤ គឺៈ ១-ការគោរពភាពចម្រុះនៃអរិយធម៌ពិភពលោក ២-ការផ្សព្វផ្សាយគុណតម្លៃ

[1] globaltimes “Spring Festival’s global reach mirrors China’s international prestige” Jan 18, 2023 https://www.globaltimes.cn/page/202301/1284035.shtml (accessed January 4, 2025 at 10:01am).
[2] Shirley Chen “On The Spring Festival, Chinese New Year and Lunar New Year: Different Perspectives Compiled” eawlc, March 10, 2023 https://www.eawlc.org/on-the-spring-festival-chinese-new-year-and-lunar-new-year-different-perspectives-compiled (accessed January 2, 2024 at 9:01am).
[3] Lili Engelhardt “A Local's Perspective on The Chinese New Year” visitchapelhill, Jan. 18, 2023 https://www.visitchapelhill.org/blog/post/a-locals-perspective-on-the-chinese-new-year/ (accessed January 9, 2025 at 1:53pm).
[4] Humprey A. Russell “China’s soft power and its Lunar New Year’s Culture” moderndiplomacy, February 18, 2018 https://moderndiplomacy.eu/2018/02/18/chinas-soft-power-lunar-new-years-culture/ (accessed January 19, 2025 at 9:14am).
[5] Gao Wencheng “Xinhua Commentary: What drives the growth of China's soft power” Xinhua, 2024-03-14 20 https://english.news.cn/20240314/d617c80dbf25477b85c1709bbec365ec/c.html (accessed January 5, 2025 at 1:44pm).

រួមនៃមនុស្សជាតិ ៣-ការយកចិត្តទុកដាក់លើការបន្តវេននិងនវានុវត្តន៍លើអរិយធម៌ និង ៤-ការពង្រឹងកិច្ចសហប្រតិបត្តិការលើការផ្លាស់ប្តូរប្រជាជននិងប្រជាជន។

តើវប្បធម៌ចូលឆ្នាំចិនមានឥទ្ធិពលយ៉ាងណា? ហើយអំណាចទន់ នៃពិធីបុណ្យចូលឆ្នាំចិនមានអ្វីខ្លះ? ឆ្លុះបញ្ចាំងជាមួយទ្រឹស្តី តើការអនុវត្តរបស់ចិនត្រឹមត្រូវដែរឬទេ?

## ២- ឥទ្ធិពលវប្បធម៌ចូលឆ្នាំចិន

ការកើនឡើងឥទ្ធិពលរបស់ចិននៅក្នុងសេដ្ឋកិច្ចពិភពលោក និងសន្តិសុខអន្តរជាតិបានជំរុញឱ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំងពីអ្នកបង្កើតគោលនយោបាយ អ្នកប្រាជ្ញ និងប្រព័ន្ធផ្សព្វផ្សាយទាក់ទងនឹងក្តីបារម្ភអំពីចិនចំពោះសន្តិភាពពិភពលោក និងសណ្តាប់ធ្នាប់អន្តរជាតិដែលមានស្រាប់។ ក្នុងនោះក៏មានការព្រួយបារម្ភជាខ្លាំងដែលថាការកើនឡើងរបស់ចិន បង្កបញ្ហាប្រឈមចំពោះក្របខណ្ឌ ដែលគ្រប់គ្រងដោយលោកខាងលិចដែរឬទេ? ចាប់តាំងពី ការឡើងកាន់អំណាចនៃមេដឹកនាំជំនាន់ថ្មីក្នុងឆ្នាំ២០១២ មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ នៅក្នុងអាកប្បកិរិយារបស់ប្រទេសលោកខាងលិច និងអាស៊ី ដែលកាន់តែមានការប្រុងប្រយ័ត្នចំពោះគោលនយោបាយការបរទេសរបស់ចិន។[6]

ចំពោះពិធីបុណ្យចូលឆ្នាំចិនវិញ គឺមានគ្រួសារជួបជុំគ្នាយ៉ាងសប្បាយរីករាយជាមួយអាហារ និងការប្រារព្ធពិធី។ ជាប្រពៃណី គ្រួសារនៅភាគខាងជើងប្រទេសចិន បរិភោគនំប៉ាវ មានន័យថានាំសំណាងល្អ។ គ្រួសារនៅភាគខាងត្បូងប្រទេសចិនបរិភោគត្រី ដែលតំណាងភាពសម្បូរបែប។ ក្នុងនោះក៏មានអាំងប៉ាវ *(ស្រោមសំបុត្រក្រហម) ដែលមានសាច់ប្រាក់នៅខាងក្នុងត្រូវបានផ្តល់ឱ្យកុមារនិងមនុស្សចាស់។ ការភ្ជាប់ជាមួយលុយ ក្នុងស្រោមសំបុត្រក្រហមត្រូវបានគេរំពឹងថានឹងផ្តល់សុភមង្គល និងពរជ័យដល់អ្នកទទួល។[7]

ទីក្រុងផ្សេងៗគ្នា ជុំវិញពិភពលោកក៏រៀបចំអ្វីៗតាមលក្ខណៈបែបចិន ចាប់តាំងពីពិព័ណ៌សិល្បៈ និងទីផ្សារហើយស្លៀកពាក់ពណ៌ក្រហម និងពណ៌មាស ដើម្បីអបអរសាទរ ការចាប់ផ្តើមចូលឆ្នាំថ្មី។ លើសពីនេះ ក្រុមហ៊ុនអន្តរជាតិបានទាញយកអត្ថប្រយោជន៍ពីព្រឹត្តិការណ៍នេះ តាមរយៈការផ្សព្វផ្សាយផលិតផលទាក់ទងនឹងវប្បធម៌ចិន។ ការកើនឡើង នៃការប្រារព្ធពិធីនេះ មិនត្រឹមតែឆ្លុះបញ្ចាំងនៅក្នុងការចូលរួមរបស់សហគមន៍ជនជាតិចិន នៅបរទេសប៉ុណ្ណោះទេ។ ប៉ុន្តែក៏មានការទទួលយកវប្បធម៌ចិនសម្របទៅតាមទំនៀមទម្លាប់ខុសៗគ្នា។ ចាប់ពីការកើនឡើងនៃពិធីបុណ្យចូលឆ្នាំចិននៅក្នុងទីក្រុងដូចជា ញូវយ៉ក ឡុងដ៍ និងប៉ារីស រហូតដល់ការដាក់បញ្ចូលវប្បធម៌ចិននៅក្នុង

---

[6] Sheng Ding "Chinese Soft Power and Public Diplomacy: An Analysis of China’s New Diaspora Engagement Policies in the Xi Era" EAI Fellows Program Working Paper Series No. 43, pdf page1.

* វប្បធម៌របស់ចិនការកែចែកអាំងប៉ាវពណ៌ក្រហម ដោយញាតិចាស់ទុំ ដូចជាឪពុកម្តាយ ជីដូនជីតា ពូមីង ចែកជូនកូនចៅ និងក្មួយៗ អំឡុងថ្ងៃចូលឆ្នាំប្រពៃណី ដើម្បីជាការជូនពរសំណាងល្អ និងសិរីសួស្តីកើតមានក្នុងឆ្នាំថ្មី។ កាលពីដើមឡើយគឺគេមិនចាំបាច់ដាក់ប្រាក់ចូលនោះទេ តែក្រោយៗមកទៀត ក៏កែប្រែទម្លាប់ភ្ជាប់មកជាមួយប្រាក់។

[7] Lili Engelhardt “A Local's Perspective on The Chinese New Year” visitchapelhill, Jan. 18, 2023 https://www.visitchapelhill.org/blog/post/a-locals-perspective-on-the-chinese-new-year/ (accessed January 9, 2025 at 1:53pm).

ម៉ូដ អាហារ និងការកម្សាន្ត ខណៈដែលព្រឹត្តិការណ៍នេះ បានក្លាយទៅជានិមិត្តរូប នៃការផ្លាស់ប្តូរវប្បធម៌ និងការប្រារព្ធពិធីរួមគ្នា។ ដូច្នេះ បុណ្យចូលឆ្នាំចិន មិនត្រឹមតែ ជាថ្ងៃសម្រាកឆ្លងឆ្នាំប៉ុណ្ណោះទេ ថែមទាំងជាមធ្យោបាយតភ្ជាប់ការស្វែងយល់ និងការចែករំលែកភាពសម្បូរបែបនៃវប្បធម៌ចិនជាមួយពិភពលោកទាំងមូល។[8]

បច្ចុប្បន្ននេះ មានប្រជាជនចំនួន១ ភាគ៥ លើពិភពលោកបានអបអរថ្ងៃបុណ្យចូលឆ្នាំចិន តាមទម្រង់ខុសៗគ្នា។[9] អំណាចទន់ នៃពិធីបុណ្យចូលឆ្នាំចិនកាន់តែមានឥទ្ធិពលថែមទៀត គឺនៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ ពិធីបុណ្យនេះត្រូវបានអង្គការ UNESCO ដាក់បញ្ចូលក្នុង **«បញ្ជីបេតិកភណ្ឌវប្បធម៌ អរូបិយនៃមនុស្សជាតិ»**។ ពិធីបុណ្យនេះត្រូវបានប្រារព្ធយ៉ាងទូលំទូលាយ ហើយក៏ជាថ្ងៃឈប់សម្រាក ដែលត្រូវបានគេចាត់ទុកថាជាថ្ងៃបុណ្យប្រពៃណីដ៏សំខាន់បំផុតរបស់ជនជាតិចិន និងជានិមិត្តរូបនៃសេចក្តីប្រាថ្នាសម្រាប់ជីវិតកាន់តែប្រសើរ។ បច្ចុប្បន្នប្រទេសចិនបានដាក់បញ្ចូលក្នុង «បញ្ជីបេតិកភណ្ឌវប្បធម៌ អរូបិយនៃមនុស្សជាតិ» ចំនួន៤៤ ដែលច្រើនជាងប្រទេសណាៗទាំងអស់ ដោយមានរាប់បញ្ចូលចាប់ពីល្ខោនប៉េកាំង ការសរសេរអក្សរផ្ចង់ប្រពៃណី និងពិធីបុណ្យអុំទូកជាដើម។[10] ឥទ្ធិពលវប្បធម៌ចូលឆ្នាំចិន មានលក្ខណៈកាន់តែពិសេសទៀតនោះ ប្រទេសជាច្រើនរួមទាំងកូរ៉េខាងត្បូង ឥណ្ឌូនេស៊ី ថៃ ម៉ាឡេស៊ី វៀតណាម និងសិង្ហបុរី បានកំណត់ថ្ងៃបុណ្យចូលឆ្នាំចិនជាថ្ងៃឈប់សម្រាកសាធារណៈ។ ម្យ៉ាងវិញទៀត ដោយសារកម្លាំងសេដ្ឋកិច្ច និងវប្បធម៌របស់ប្រទេសចិន ពិធីបុណ្យនេះកំពុងក្លាយជានិមិត្តរូប នៃវប្បធម៌ពិភពលោក។[11]

## ៣- អំណាចទន់

អំណាចទន់ ជាវិធីសាស្ត្រទស្សនទានដ៏សំខាន់មួយ ក្នុងការយល់ដឹង អំពីគោលនយោបាយការបរទេសរបស់រដ្ឋមួយ ត្រូវបានទទួលយកដោយអ្នកបង្កើតគោលនយោបាយរបស់ប្រទេសចិន ហើយបានអនុវត្ត ចំពោះគំនិតផ្តួចផ្តើមគោលនយោបាយការបរទេសជាច្រើន របស់ប្រទេសក្នុងអំឡុងពេលបញ្ចប់សង្គ្រាម បន្ទាប់មានពីការសម្លាប់រង្គាលនៅទីលានធានអានមេន។ នៅឆ្នាំ១៩៨៩ មេដឹកនាំចិនបានបន្តសង្កត់ធ្ងន់លើតួនាទីនៃការទូតសាធារណៈក្នុងការអភិវឌ្ឍ និងកាន់អំណាចទន់របស់ចិន។ ជនភៀសខ្លួនចិន៤១លាននាក់ រួមទាំងពលរដ្ឋបរទេសទាំងដើមកំណើតចិន និងពលរដ្ឋចិនដែលរស់នៅក្រៅប្រទេស បានក្លាយជាកត្តាសំខាន់កាន់តែខ្លាំងឡើងនៅក្នុងទំនាក់ទំនងការទូតសាធារណៈរបស់ប្រទេសចិន។[12] ចំណែកឯទំនាក់ទំនងចិន-អាម៉េរិកក៏មានការប្រកួតប្រជែងកាន់តែខ្លាំងឡើង ក្នុងវិស័យពាណិជ្ជកម្ម បច្ចេកវិទ្យាទំនើប និងផលប្រយោជន៍យុទ្ធសាស្ត្រ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហា «អំណាច

---

[8] groups3 “Chinese New Year 2025: tradition, culture and... its impact on imports” 14/01/2025 https://www.groups3.com/chinese-new-year-2025-tradition-culture-and-its-impact-on-imports/ (accessed January 29, 2025 at 3:21pm).

[9] តាំង ស៊ីឡេង៖ ចុះផ្សាយថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៥ "គុណតម្លៃនៃបុណ្យចូលឆ្នាំចិន និងអត្ថន័យនៃឆ្នាំម្សាញ់ក្នុងអរិយធម៌និងវប្បធម៌ចិន" https://freshnewsasia.com/index.php/en/internationalnews/374409-2025-01-24-09-50-46.html (accessed January 25, 2025 at 10:01am)។

[10] Li Xin “China Rejoices as UNESCO Recognizes Spring Festival” sixthtone, Dec 05, 2024 https://www.sixthtone.com/news/1016326 (accessed January 11, 2025 at 9:58am).

[11] globaltimes “Spring Festival’s global reach mirrors China’s international prestige” Jan 18, 2023 https://www.globaltimes.cn/page/202301/1284035.shtml (accessed January 4, 2025 at 10:01am).

[12] Sheng Ding "Chinese Soft Power and Public Diplomacy: An Analysis of China’s New Diaspora Engagement Policies in the Xi Era" EAI Fellows Program Working Paper Series No. 43, pdf page2.

ទន់» ដូចជាកិត្យានុភាព និងភាពស្របច្បាប់ក៏កំពុងត្រូវបានប្រកួតប្រជែងផងដែរ។ ប្រទេសទាំងពីរកំពុងព្យាយាមទាក់ទាញជនបរទេស និងអ្នកបង្កើតគោលនយោបាយតាមរយៈការសន្យា នៃការពឹងពាក់គ្នាទៅវិញទៅមក ស្របពេលដែលពួកគេត្រូវចាប់ផ្តើមនិយាយតិច និងធ្វើសកម្មភាពកាន់តែច្រើន។[13]

យោងតាមទស្សនៈវិទូ ខុង ជឺ ដែលបានមានប្រសាសន៍នៅប្រហែល៥០០ឆ្នាំមុនគ្រិស្តសករាជថា ***«នៅពេលអ្នកច្បាស់ថា មិនអាចទៅដល់គោលដៅ សូមកុំកែប្រែគោលដៅ ប៉ុន្តែត្រូវកែប្រែរបៀបដើររបស់អ្នកវិញ»***។ នេះជាអ្វី ដែលចិនចាប់ផ្តើមធ្វើកាលពីមួយទសវត្សរ៍មុនក្នុងការចាប់យកគោលគំនិតនៃអំណាចទន់។ នៅឯសមាជបក្សលើកទី១៧ ក្នុងឆ្នាំ២០០៧ លោកប្រធានាធិបតី ហ៊ូ ជីនតាវ (Hu Jintao) បាននិយាយអំពីតម្រូវការថា **«ការពង្រឹងវប្បធម៌ ជាផ្នែកមួយនៃអំណាចទន់ របស់ប្រទេសយើង (ចិន)»**។ លោកបានមានប្រសាសន៍ថា គោលដៅដែលប្រទេសចិនប្រាថ្នាចង់សម្រេចបានគឺ **«ដើម្បីធានាឱ្យបានកាន់តែប្រសើរឡើងនូវប្រសិទ្ធិភាព និងផលប្រយោជន៍ វប្បធម៌ជាមូលដ្ឋានរបស់ប្រជាជន ពង្រឹងជីវភាពវប្បធម៌នៅក្នុងសង្គមចិន និងជំរុញប្រជាជនឱ្យមានការរីកចម្រើន»**។[14]

ជាការពិតណាស់ការចំណាយរបស់ប្រទេសចិនលើអំណាចទន់ ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ បានកើនឡើងដល់១០ប៊ីលានដុល្លារក្នុងមួយឆ្នាំ (គិតត្រឹមឆ្នាំ២០១៧) នេះបើយោងតាមលោក David Shambaugh នៃសាកលវិទ្យាល័យ George Washington។ ការចំណាយនេះ គឺច្រើនជាងការចំណាយរបស់រដ្ឋាភិបាលរួមគ្នា របស់សហរដ្ឋអាម៉េរិក ចក្រភពអង់គ្លេស បារាំង អាល្លឺម៉ង់ និងជប៉ុនលើអំណាចទន់។[15]

ចំណែកទស្សនៈរបស់លោក Joseph Nye, Jr (កើតនៅថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៣៧) ដែលអ្នកវិទ្យាសាស្ត្រនយោបាយជនជាតិអាមេរិកថា **«រូបិយប័ណ្ណនៃអំណាចទន់គឺវប្បធម៌, តម្លៃនយោបាយ, និងគោលនយោបាយបរទេស។ ក្នុងអំឡុងពេលនៃយុគសម័យព័ត៌មាន ភាពជឿជាក់គឺជាធនធានដ៏កម្របំផុត»**។ ដោយយល់ឃើញបែបនេះ ប្រទេសចិនបានចូលរួមជាលំដាប់ក្នុងការផ្សព្វផ្សាយវប្បធម៌បរទេស។[16] តាមទ្រឹស្តីរបស់លោក ចិនមានសមត្ថភាពក្នុងការធ្វើឱ្យមានឥទ្ធិពលលើអ្នកដទៃ តាមរយៈការទាក់ទាញ ជាជាងការបង្ខិតបង្ខំ។ អំណាចទន់ របស់ចិនអាចលើកកម្ពស់យ៉ាងសំខាន់ នូវជំហរសកល និងប្រសិទ្ធភាពរបស់ខ្លួន ក្នុងវិស័យការទូត។ លោក Joseph Nye ថា **ប្រភពមួយ នៃអំណាចទន់របស់ចិន គឺជាវប្បធម៌ប្រពៃណីរបស់ចិន ដែលនៅតែទាក់ទាញ**។[17]

---

[13] DR DANIELE CARMINATI "Soft power through connectivity: How do China and the US compare?" 5 July 2023 https://www.9dashline.com/article/soft-power-through-connectivity-how-do-china-and-the-us-compare (accessed January 28, 2024 at 9:44am).
[14] Martin Davidson "China's Soft Power: A Comparative Failure or Secret Success" uscpublicdiplomacy, Aug 25, 2017 https://uscpublicdiplomacy.org/blog/chinas-soft-power-comparative-failure-or-secret-success (accessed January 28, 2025 at 10:12am).
[15] Ibid.
[16] Humprey A. Russell "China's soft power and its Lunar New Year's Culture" moderndiplomacy, February 18, 2018 https://moderndiplomacy.eu/2018/02/18/chinas-soft-power-lunar-new-years-culture/ (accessed January 19, 2025 at 9:14am).
[17] Gao Wencheng "Xinhua Commentary: What drives the growth of China's soft power" Xinhua, 2024-03-14 20 https://english.news.cn/20240314/d617c80dbf25477b85c1709bbec365ec/c.html (accessed January 5, 2025 at 1:44pm).

ក្រោមការដឹកនាំរបស់លោកប្រធានាធិបតី ស៊ី ជីនភីង ដែលបានឡើងកាន់អំណាចនៅចុងឆ្នាំ២០១២ កិច្ចខិតខំប្រឹងប្រែង អំណាចទន់បានធ្វើឱ្យ មានភាពបន្ទាន់ខ្លាំងជាងមុនទៀត។ លោកបានបន្តដាស់តឿនកម្មាភិបាលឱ្យធ្វើការលើការពង្រឹងអំណាចទន់របស់ប្រទេសចិន។ ចាប់តាំងពីឆ្នាំ២០១០មក ក្រសួងវប្បធម៌របស់ប្រទេសចិនបានបញ្ចូលកម្លាំងទៅក្នុងការរៀបចំព្រឹត្តិការណ៍បុណ្យចូលឆ្នាំចិនយ៉ាងច្រើន នៅទូទាំងពិភពលោក តាមរយៈភាពជាដៃគូជាមួយអង្គភាពធុរកិច្ចនៅក្រៅប្រទេស និងអង្គការវប្បធម៌។[18] ចំពោះអំណាចទន់លោក ស៊ី ជីនភីង បានមានប្រសាសន៍ថា «**ដើម្បីពង្រឹងអំណាចទន់របស់ប្រទេសចិន ប្រទេសនេះត្រូវកសាងសមត្ថភាពរបស់ខ្លួនក្នុងទំនាក់ទំនងអន្តរជាតិ បង្កើតប្រព័ន្ធទំនាក់ទំនង ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយថ្មីឱ្យកាន់តែប្រសើរឡើង និងបង្កើនការច្នៃប្រឌិត ការអំពាវនាវ និងភាពជឿជាក់នៃការផ្សព្វផ្សាយរបស់ប្រទេសចិន។ រឿងរ៉ាវរបស់ចិន គួរតែនិយាយបានល្អ សំឡេងរបស់ចិនបានសាយភាយល្អ ហើយលក្ខណៈរបស់ចិនពន្យល់បានល្អ**»។[19]

ប្រទេសចិនបានបន្តកំណែទម្រង់អន្តោប្រវេសន៍ថ្មីដើម្បីយកឈ្នះចិត្តនិងបេះដូងរបស់ជនជាតិចិននៅឯបរទេស ដែលជាយុទ្ធសាស្ត្រទំនាក់ទំនងអន្តរជាតិថ្មី ដើម្បីកែលម្អមុខមាត់ជាតិរបស់ប្រទេសចិន ជាមួយយុទ្ធនាការវប្បធម៌និងការអប់រំថ្មី ដើម្បីកំណត់អត្តសញ្ញាណវប្បធម៌របស់ជនជាតិចិនក្រៅប្រទេស។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មេដឹកនាំចិន បានអនុម័តនូវគោលនយោបាយភ្ជាប់ទំនាក់ទំនងថ្មីជាបន្តបន្ទាប់ ដើម្បីពង្រឹងអំណាចទន់របស់ចិន និងបញ្ជូនគំនិតរបស់ចិនទៅកាន់ពិភពខាងក្រៅ។[20]

## ៤- សន្និដ្ឋាន

សរុបមក ពិធីបុណ្យចូលឆ្នាំចិន មានប្រវត្តិជាយូរណាស់មកហើយ តែពាក្យបុណ្យចូលឆ្នាំចិន នៅប្រើប្រាស់ជាច្រើនប្រភេទ។ គោលបំណងសកម្មភាពអតីតកាលចិនដេញសត្វសាហាវ តែបច្ចុប្បន្នជាការរៀបចំកម្មវិធីយ៉ាងសប្បាយរីករាយ រហូតដល់ភាពរីករាយនេះបានហូរចូលស្ទើរគ្រប់ប្រទេសលើសកលលោក។ តែអំណាចទន់របស់ចិនក៏មានគូប្រជែងជាមួយសហរដ្ឋអាម៉េរិកនិងសម្ព័ន្ធមិត្តរបស់សហរដ្ឋអាម៉េរិកផងដែរ។

ភាពសំខាន់នៃអំណាចទន់របស់ចិនគឺ ១-បន្ទាប់ពីមានការកែទម្រង់និងបើកចំហ ២-វិវត្តន៍ទៅតាមសម័យទំនើបនៃបច្ចេកវិជ្ជា និងការលូតលាស់សេដ្ឋកិច្ចឥតឈប់ឈររបស់ចិន បានធ្វើឱ្យប្រទេសផ្សេងទៀតចង់ដឹងពីរបៀបដែលចិនរីកចម្រើនរហូតដល់បរទេសយកគំរូទាំងវប្បធម៌និងសេដ្ឋកិច្ចរបស់ចិន។ ៣-ចិនជាមហាអំណាចសេដ្ឋកិច្ចទី២លើពិភពលោក ជារឿងដែលអន្តរជាតិតាមដានរាល់ទង្វើរបស់ចិន ៤-គោលដៅជាមហាអំណាចរបស់ចិនមិនកែប្រែទិសដៅ តែចិនគ្រាន់តែកែប្រែរបៀបដើរតែប៉ុណ្ណោះ ៥-ការយកចិត្តទុកដាក់វប្បធម៌នៃជីវភាពប្រជាជន។

---

[18] Julie Makinen "Beijing uses Chinese New Year to push China's soft power" latimes, Feb. 18, 2015 https://www.latimes.com/world/asia/la-fg-china-new-year-20150218-story.html (accessed January 4, 2025 at 9:37am).

[19] Sheng Ding "Chinese Soft Power and Public Diplomacy: An Analysis of China's New Diaspora Engagement Policies in the Xi Era" EAI Fellows Program Working Paper Series No. 43, pdf page1.

[20] Sheng Ding "Chinese Soft Power and Public Diplomacy: An Analysis of China's New Diaspora Engagement Policies in the Xi Era" EAI Fellows Program Working Paper Series No. 43, pdf page2.

ការទាញយកប្រយោជន៍អំណាចទន់របស់ចិន ១-អំណាចទន់របស់ចិន ដែលទទួលបានបច្ចុប្បន្នមិនមែនចិនទើបតែចាប់ផ្ដើមធ្វើនោះទេ តែចិនបានចាប់ផ្ដើមយូរមកហើយ ២-ពិធីបុណ្យរបស់ចិនកាន់តែមានតម្លៃបន្ទាប់ពីបានចុះបញ្ជីបេតិកភណ្ឌវប្បធម៌ អរូបិយនៃមនុស្សជាតិ ៣-ប្រទេសផ្សេងៗបានរងឥទ្ធិពលអំណាចទន់នៃវប្បធម៌របស់ចិន។ ៤-លទ្ធភាពសេដ្ឋកិច្ចរបស់ចិនបានធ្វើឱ្យចិនមានថវិកាច្រើនក្នុងការផ្សព្វផ្សាយវប្បធម៌កាន់តែទូលំទូលាយ ៥-ចិនអាចលក់សម្ភារៈទាក់ទងវប្បធម៌យ៉ាងច្រើន ៦-អំណាចទន់របស់ចិនមិនមែនមានវិសាលភាពត្រឹមវប្បធម៌ តែមានទាំងនយោបាយ និងគោលនយោបាយការបរទេស ៧-ការចំណាយរបស់ចិននៅតែជានុយ ដើម្បីទាញផលប្រយោជន៍មកវិញ។

បច្ចុប្បន្ននិងអនាគតនៃអំណាចទន់របស់វប្បធម៌អាចទទួលយកប្រយោជន៍សេដ្ឋកិច្ចយ៉ាងសម្បើមតាមរយៈវិស័យទេសចរណ៍ ប៉ុន្តែត្រូវការជង្ហើមនៃសន្តិសុខប្រពៃណី និងសន្តិសុខមិនប្រពៃណី។ នៅពេលដែលភូមិទី១ មានកម្មវិធីបុណ្យភូមិរាំជុំគ្នាសប្បាយ ប៉ុន្តែភូមិទី២ បានទទួលព័ត៌មានថានៅភូមិទី១មានអំពើឆក់ប្លន់ច្រើន ដូច្នេះអ្នកភូមិទី១មិនហ៊ានទៅលេងនៅទីនោះទេ៕

# ឯកសារយោង៖


1. globaltimes “Spring Festival’s global reach mirrors China’s international prestige” Jan 18, 2023 https://www.globaltimes.cn/page/202301/1284035.shtml (accessed January 4, 2025 at 10:01am).
2. Shirley Chen “On The Spring Festival, Chinese New Year and Lunar New Year: Different Perspectives Compiled” eawlc, March 10, 2023 https://www.eawlc.org/on-the-spring-festival-chinese-new-year-and-lunar-new-year-different-perspectives-compiled (accessed January 2, 2024 at 9:01am).
3. Lili Engelhardt “A Local's Perspective on The Chinese New Year” visitchapelhill, Jan. 18, 2023 https://www.visitchapelhill.org/blog/post/a-locals-perspective-on-the-chinese-new-year/ (accessed January 9, 2025 at 1:53pm).
4. Humprey A. Russell “China’s soft power and its Lunar New Year’s Culture” moderndiplomacy, February 18, 2018 https://moderndiplomacy.eu/2018/02/18/chinas-soft-power-lunar-new-years-culture/ (accessed January 19, 2025 at 9:14am).
5. Gao Wencheng “Xinhua Commentary: What drives the growth of China's soft power” Xinhua, 2024-03-14 20 https://english.news.cn/20240314/d617c80dbf25477b85c1709bbec365ec/c.html (accessed January 5, 2025 at 1:44pm).
6. Sheng Ding "Chinese Soft Power and Public Diplomacy: An Analysis of China’s New Diaspora Engagement Policies in the Xi Era" EAI Fellows Program Working Paper Series No. 43, pdf page1.
7. Lili Engelhardt “A Local's Perspective on The Chinese New Year” visitchapelhill, Jan. 18, 2023 https://www.visitchapelhill.org/blog/post/a-locals-perspective-on-the-chinese-new-year/ (accessed January 9, 2025 at 1:53pm).
8. groups3 “Chinese New Year 2025: tradition, culture and... its impact on imports” 14/01/2025 https://www.groups3.com/chinese-new-year-2025-tradition-culture-and-its-impact-on-imports/ (accessed January 29, 2025 at 3:21pm).
9. តាំង ស៊ីឡេង៖ ចុះផ្សាយថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៥ "គុណតម្លៃនៃបុណ្យចូលឆ្នាំចិន និងអត្ថន័យនៃឆ្នាំម្សាញ់ក្នុងអរិយធម៌ និងវប្បធម៌ចិន" https://freshnewsasia.com/index.php/en/internationalnews/374409-2025-01-24-09-50-46.html (accessed January 25, 2025 at 10:01am)។
10. Li Xin “China Rejoices as UNESCO Recognizes Spring Festival” sixthtone, Dec 05, 2024 https://www.sixthtone.com/news/1016326 (accessed January 11, 2025 at 9:58am).
12. Sheng Ding "Chinese Soft Power and Public Diplomacy: An Analysis of China’s New Diaspora Engagement Policies in the Xi Era" EAI Fellows Program Working Paper Series No. 43, pdf page2.
13. DR DANIELE CARMINATI “Soft power through connectivity: How do China and the US compare?” 5 July 2023 https://www.9dashline.com/article/soft-power-through-connectivity-how-do-china-and-the-us-compare (accessed January 28, 2024 at 9:44am).
14. Martin Davidson “China's Soft Power: A Comparative Failure or Secret Success” uscpublicdiplomacy, Aug 25, 2017 https://uscpublicdiplomacy.org/blog/chinas-soft-power-comparative-failure-or-secret-success (accessed January 28, 2025 at 10:12am).
15. Humprey A. Russell “China’s soft power and its Lunar New Year’s Culture” moderndiplomacy, February 18, 2018 https://moderndiplomacy.eu/2018/02/18/chinas-soft-power-lunar-new-years-culture/ (accessed January 19, 2025 at 9:14am).
16. Gao Wencheng “Xinhua Commentary: What drives the growth of China's soft power” Xinhua, 2024-03-14 20 https://english.news.cn/20240314/d617c80dbf25477b85c1709bbec365ec/c.html (accessed January 5, 2025 at 1:44pm).
17. Julie Makinen “Beijing uses Chinese New Year to push China’s soft power” latimes, Feb. 18, 2015 https://www.latimes.com/world/asia/la-fg-china-new-year-20150218-story.html (accessed January 4, 2025 at 9:37am).